ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ០២ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការដំឡើងការិយាល័យអាជីវកម្មរ៉ែ និងថ្មសំភារៈសំណង់ នៃនាយកដ្ឋានធនធានរ៉ែ ទៅជានាយកដ្ឋានរ៉ែសំណង់ ចំណុះអគ្គនាយកដ្ឋានធនធានរ៉ែ នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និង រដ្ឋលេខាធិការដ្ឋាន

-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

សម្រេច

មាត្រា១ : ដំឡើងការិយាល័យអាជីវកម្មរ៉ែ និងថ្មសំភារៈសំណង់ នៃនាយកដ្ឋានធនធានរ៉ែទៅជានាយកដ្ឋានរ៉ែសំណង់ ចំណុះអគ្គនាយកដ្ឋានធនធានរ៉ែ នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

មាត្រា២ : នាយកដ្ឋានរ៉ែសំណង់ មានតួនាទី និងភារកិច្ច ដូចតទៅ :

- រៀបចំគោលការណ៍នានាដែលទាក់ទងដល់ការស្វែងរុករក និងការធ្វើអាជីវកម្មរ៉ែសំណង់ ដែលមានជាអាទិ៍ : ថ្មអារ ថ្មសំណង់ ក្រួស ខ្សាច់សំណង់ ដីឥដ្ឋសំណង់ ឡាតេរីត និងអាចម៍ដី ។

www.pheakdeylaw.com

- សិក្សា វិភាគ និងវាយតម្លៃសក្តានុពលធនធានរ៉ែសំណង់ លើផ្នែកបរិមាណ គុណភាព និង សេដ្ឋកិច្ច ។
- ត្រួតពិនិត្យ និងគ្រប់គ្រងការធ្វើអាជីវកម្មធនធានរ៉ែសំណង់ ។
- រៀបចំស្ថិតិផលិតកម្ម-អាជីវកម្មធនធានរ៉ែសំណង់ ។
- គ្រប់គ្រង ត្រួតពិនិត្យផលប៉ះពាល់បរិស្ថាន ការស្តារបរិស្ថាន និងសុវត្ថិភាពពលកម្ម ។
- សហការ/ពិនិត្យផ្តល់មតិលើផ្នែកបច្ចេកទេសអាជីវកម្ម ឬជីកយក និង វាយតម្លៃរបាយការណ៍ បច្ចេកទេសរបស់ក្រុមហ៊ុន/ សម្បទានិក ។
- គ្រប់គ្រង ណែនាំ ពិនិត្យ និងតាមដានការអនុវត្តន៍ច្បាប់ អនុក្រឹត្យ បទប្បញ្ញត្តិ និង បទបញ្ជានានា។
- លើកគំរោង អនុវត្តកិច្ចសហប្រតិបត្តិការជាមួយស្ថាប័ន អង្គការជាតិ និងអន្តរជាតិ ។

មាត្រា៣ : នាយកដ្ឋានរ៉ែសំណង់ ដឹកនាំដោយប្រធាន ០១ រូប និង អនុប្រធានមួយចំនួនជាជំនួយការតាម ការចាំបាច់។

មាត្រា៤ : រចនាសម្ព័ន្ធព្រមទាំងការរៀបចំ និង ការប្រព្រឹត្តទៅរបស់នាយកដ្ឋានរ៉ែសំណង់ ត្រូវកំណត់ដោយ ប្រកាសរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល។

មាត្រា៥ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

មាត្រា៦ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការដ្ឋានគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវទទួលបន្ទុក អនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០០៨

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រីសូមហត្ថលេខា
រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

ស៊ុយ សែម

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៦
- កាលប្បវត្តិ-ឯកសារ

www.pheakdeylaw.com